# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ សរ

## សារាចរ

## ស្តីពី

## ការផ្សាយពាណិជ្ជកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា

កន្លងមករាជរដ្ឋាភិបាលបានកត់សំគាល់ឃើញថា គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនបានផ្សាយពាណិជ្ជកម្មអំពីសេវាអប់រំ និង លក្ខណសម្បត្តិនៃគ្រឹះស្ថានឧត្តមសិក្សារបស់ខ្លួនពុំត្រឹមត្រូវ បំផ្លើសការពិត ដើម្បីទាក់ទាញនិស្សិតឱ្យចូលសិក្សាតាមគ្រប់រូបភាព រួមមាន ការផ្សាយតាមទូរទស្សន៍ តាមវិទ្យុ តាមសារពត៌មាន តាមប្រព័ន្ធអេឡិចត្រូនិច តាមខិត្តប័ណ្ណ/ឧក្សោសនស័ព្ទ តាមការចងបដា និងតាមមធ្យោបាយផ្សេងៗ ជាច្រើនទៀត ។

ដើម្បីធានាបាននូវការគោរពច្បាប់ជាធរមាន ជាពិសេសច្បាប់ស្តីពីរបបសារព័ត៌មាន និងព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា សំដៅរក្សាគុណភាពសិក្សា និង កិត្យានុភាពជាតិ ជៀសវាងនូវផលប៉ះពាល់អវិជ្ជមាននានា ដល់និស្សិត និង សង្គមជាតិទាំងមូល រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម ÷

១-គ្រឹះស្ថានឧត្តមសិក្សាទាំងឡាយដែលទទួលបានការអនុញ្ញាតឱ្យបង្កើត ការទទួលស្គាល់និងការអនុញ្ញាតឱ្យបន្តដំណើរការជាផ្លូវការពីរាជរដ្ឋាភិបាល អាចផ្សាយពាណិជ្ជកម្មអំពីសេវាអប់រំ និងលក្ខណសម្បត្តិនៃគ្រឹះស្ថានឧត្តមសិក្សារបស់ខ្លួនបាន ដោយបញ្ជាក់នូវលក្ខណៈពិតប្រាកដជាក់ស្តែងគ្មានបំផ្លើស ។

២-គ្រឹះស្ថានឧត្តមសិក្សា ឬ សាខាណា ដែលពុំទាន់ទទួលបានការអនុញ្ញាតឱ្យបង្កើត ការទទួលស្គាល់ ការអនុញ្ញាតឱ្យបន្តដំណើរការជាផ្លូវការពីរាជរដ្ឋាភិបាល ឬ ក្រសួងអប់រំ យុវជន និងកីឡា ទេនោះ មិនត្រូវអនុញ្ញាតឱ្យធ្វើការផ្សាយពាណិជ្ជកម្មសេវាអប់រំ និង ជ្រើសរើសនិស្សិតអោយចូលសិក្សាឡើយ ។ អ្នកប្រព្រឹត្តល្មើសនឹងការណែនាំនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

៣-ហាមឃាត់ដាច់ខាតរាល់ការផ្សាយពាណិជ្ជកម្ម តាមគ្រប់រូបភាពដែលមានលក្ខណៈពុំត្រឹមត្រូវ បំផ្លើសពីការពិតនៃសេវាអប់រំ និង លក្ខណសម្បត្តិនៃគ្រឹះស្ថានឧត្តមសិក្សារបស់ខ្លួន ។ អ្នកប្រព្រឹត្តល្មើសនឹងការណែនាំនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

៤-រាល់ខ្លឹមសារ និង រូបភាពនៃការផ្សាយពាណិជ្ជកម្មសិក្សា ត្រូវមានទិដ្ឋាការអនុញ្ញាតពីគណៈកម្មការរបស់ក្រសួងអប់រំ យុវជន និង កីឡា ដែលមានសមាសភាពចូលរួមពី គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។ គណៈកម្មការរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពិនិត្យ និងផ្តល់ទិដ្ឋាការក្នុងរយៈពេលយ៉ាងយូរ៧ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីកាលបរិច្ឆេទទទួលពាក្យសុំ ប្រសិនបើខ្លឹមសារស្នើសុំផ្សាយពុំមានកំហុសឆ្គង។ ករណីមានការខុសឆ្គង ឬមានពាក់ព័ន្ធទៅនឹងការស្រាវជ្រាវបន្ថែម រយៈពេលនៃការពិនិត្យ និងផ្តល់ទិដ្ឋាការ ត្រូវមានរយៈពេលមិនលើសពី ៤ សប្តាហ៍។

៥-ករណីគ្រឹះស្ថានឧត្តមសិក្សាធ្វើការផ្សាយពាណិជ្ជកម្មសិក្សាដែលមាន ខ្លឹមសារ និង រូបភាព ផ្ទុយនឹងទិដ្ឋាការអនុញ្ញាត ឬ ធ្វើការផ្សាយពាណិជ្ជកម្មសិក្សាដោយគ្មានទិដ្ឋាការអនុញ្ញាត គណៈកម្មការរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវជូនដំណឹងទៅគ្រឹះស្ថានឧត្តមសិក្សាសាមីឱ្យកែតម្រូវ ឬបញ្ឈប់ការផ្សាយពាណិជ្ជកម្មរបស់ខ្លួនជាបន្ទាន់ ។ ក្នុងករណីគ្រឹះស្ថានឧត្តមសិក្សានោះមិនព្រមធ្វើការកែតម្រូវ ឬមិនព្រមបញ្ឈប់ការផ្សាយ គណៈកម្មការរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវជម្រាបទៅក្រសួងព័ត៌មានឱ្យជូនដំណឹងដល់បណ្តាញសារព័ត៌មានដែលពាក់ព័ន្ធ ដើម្បីឱ្យផ្អាកការផ្សាយ ពាណិជ្ជកម្មរបស់គ្រឹះស្ថានឧត្តមសិក្សានោះ ជាបន្ទាន់។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួង និងរដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងគ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវអនុវត្តខ្លឹមសារណែនាំខាងលើ ដោយស្មារតីទទួលខុសត្រូវ និងឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ